**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

លេខ: ០១៤២ សដល·អក·មអជ

ថ្ងៃ ព្រហស្បតិ៍ ៥កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនប្រជាពលរដ្ឋ និងអ្នកកាន់អាជ្ញាបណ្ណផ្គត់ផ្គង់សេវាកម្មអគ្គិសនីនៅតំបន់ជនបទឲ្យបានជ្រាបថាៈ អគ្គិសនីកម្ពុជាបានផ្តល់ថវិកាជាអំណោយដល់នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា (បន្ទាប់ពីនេះទៅហៅថា "ម.អ.ជ.") ដើម្បីបន្តអនុវត្តន៍ "កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណក្រីក្រ (ប័ណ្ណសមធម៌) ចំនួន 1,500គ្រួសារ។ គោលបំណងនៃកម្មវិធី គឺជួយដល់គ្រួសារក្រីក្រមានប័ណ្ណក្រីក្រ (អ្នកទទួលផល) នៅតំបន់ជនបទអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ថវិកាឧបត្ថម្ភធនតាមរយៈអ្នកកាន់អាជ្ញាបណ្ណសម្រាប់ ១- ចំណាយលើសម្ភារៈ និងរាយខ្សែបណ្តាញសេវាកម្មពីចំណុចភ្ជាប់ចរន្ត (នាឡិកាស្ទង់លើបង្គោល) មកដល់ផ្ទះ និង ២- ចំណាយលើការរៀបចំខ្សែបណ្តាញ និងសម្ភារៈអគ្គិសនីក្នុងផ្ទះដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ ចំនួនទឹកប្រាក់ឧបត្ថម្ភធន គឺ ១០០ដុល្លារអាមេរិក ក្នុង១គ្រួសារ។ អ្នកទទួលផលត្រូវបង់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនីសរុបចំនួន ១២២.០០០រៀល សម្រាប់ការតភ្ជាប់ចរន្តកម្លាំង ១០អំពែរ និងត្រូវផ្តល់បង្គោលឈើទ្រខ្សែចម្លងពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះ។ អ្នកទទួលផលនឹងក្លាយជាម្ចាស់កម្មសិទ្ធិខ្សែបណ្តាញសេវាកម្ម និងសម្ភារៈអគ្គិសនីក្នុងផ្ទះ បន្ទាប់ពីអ្នកទទួលផលបានបង់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនីឲ្យអ្នកកាន់អាជ្ញាបណ្ណគ្រប់ចំនួន។ កម្មវិធីនេះ ជាកម្មវិធីអនុវត្តន៍បន្តពីឆ្នាំ២០១៧ និងនៅបន្តអនុវត្តន៍ក្នុងឆ្នាំ២០១៩។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់តារា ទូរស័ព្ទលេខ 015 776-770 / 011 244-246 ឬលោក ថាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 089 776-770 / 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅនាយកដ្ឋាន ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**

**ចម្លងជូនៈ**

- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "ជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ